**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ.......០០៦/១១...គ.ម.ក ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

Downloaded from http://www.khmerlaws.com

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធប្រកាសលេខ ..០០៦/១១ គ.ម.ក.ប្រ.ក.
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានប្រតិបត្តិការទីផ្សារមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់នូវគោលការណ៍ចាំបាច់នានាសម្រាប់ការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលទទួលបានការអនុញ្ញាតស្របតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

- **សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្ររបស់ **ផ.ម.ក.** និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ **ផ.ម.ក.**។

- **ការបញ្ជា** សំដៅដល់ការបញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅ **ផ.ម.ក.**។

- **ថ្ងៃបើក** សំដៅដល់ថ្ងៃជួញដូរដំបូងនៃមូលបត្រនៅក្នុង **ផ.ម.ក.** នៅថ្ងៃជួញដូរនីមួយៗ។

- **ថ្ងៃបិទ** សំដៅដល់ថ្ងៃជួញដូរចុងក្រោយនៃមូលបត្រ ដែលត្រូវបានកំណត់មុនពេលបិទម៉ោងជួញដូរនៅថ្ងៃជួញដូរនីមួយៗ រួមទាំងថ្ងៃពិសេសផងដែរ។



Downloaded from http://www.khmerlaws.com

- **ថ្លៃពិសេស** សំដៅដល់សំណើថ្លៃលក់ល្អបំផុត (Best Offer) ក្នុងករណីដែលថ្លៃលក់ទាបជាងថ្លៃមូលដ្ឋាន ឬសំណើថ្លៃទិញល្អបំផុត (Best Bid) ក្នុងករណីដែលថ្លៃទិញខ្ពស់ជាងថ្លៃមូលដ្ឋានសម្រាប់មូលបត្រដែលមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទទីផ្សារ។

- **ប្រតិបត្តិការគណនីអតិថិជន** សំដៅដល់ការទិញ ឬលក់មូលបត្រ បន្ទាប់ពីបានទទួលការបញ្ជាពីអតិថិជន។

- **ប្រតិបត្តិការគណនីសមាជិក** សំដៅដល់ការទិញ ឬលក់មូលបត្រ សម្រាប់គណនីផ្ទាល់របស់សមាជិក។

- **ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.** សំដៅដល់ប្រព័ន្ធកុំព្យូទ័រដែលប្រតិបត្តិដោយ **ផ.ម.ក.** ក្នុងគោលបំណងធ្វើជាអន្តរការីនៃការជួញដូរមូលបត្រ។

- **ប្រព័ន្ធកុំព្យូទ័រសមាជិក** សំដៅដល់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិក ដែលត្រូវបានអនុញ្ញាតឱ្យបញ្ជូនការបញ្ជាទៅកាន់ប្រព័ន្ធកុំព្យូទ័ររបស់ **ផ.ម.ក.**។

- **ការជួញដូរមិនប្រក្រតី** សំដៅដល់ការជួញដូរទាំងឡាយ ដែលក្នុងនោះថ្លៃឬបរិមាណជួញដូរលើមូលបត្រមានការប្រែប្រួលខុសប្រក្រតីនៅក្នុងទីផ្សារ។

- **ការជួញដូរមិនស្មោះត្រង់** សំដៅដល់ការជួញដូរដែលធ្វើឱ្យថ្លៃទីផ្សារមានការប្រែប្រួលដោយមធ្យោបាយមិនស្មោះត្រង់ដូចជា : ការប្រើប្រាស់ព័ត៌មានដែលមិនបានផ្សព្វផ្សាយ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ការប្រើឧបាយកលក្នុងទីផ្សារ ឬការផ្សព្វផ្សាយព័ត៌មានអំពីការដាក់ថ្លៃលើទីផ្សារ។

- **ការត្រួតពិនិត្យទីផ្សារ** សំដៅដល់ការឃ្លាំមើលនិងវិភាគអំពីប្រតិបត្តិការមូលបត្រនៅលើទីផ្សារ ស្ថានភាពនៃបញ្ជានិងការដាក់ថ្លៃសម្រាប់ប្រតិបត្តិការទាំងនោះ ឬការប្រកាសព័ត៌មានដែលពាក់ព័ន្ធឯកសារផ្តល់ព័ត៌មាន ពាក្យចចាមអារ៉ាម និងរបាយការណ៍សារព័ត៌មានជាដើម។

**ប្រការ ៣.- ប្រភេទមូលបត្រដែលត្រូវជួញដូរ**

មូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យជួញដូរនៅ **ផ.ម.ក.** ដោយគោរពតាមវិធាននេះ។

ការជួញដូរមូលបត្រក្នុងចំណោមសមាជិក ត្រូវបានធ្វើអន្តរការីកម្មដោយ **ផ.ម.ក.**។

**ប្រការ ៤.- សុពលភាពនៃការបញ្ជា**

រាល់ការបញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** រហូតដល់ពេលដែលការបញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ សុពលភាពនៃការបញ្ជាអាចត្រូវបានព្យួរក្នុងករណីដែលការជួញដូរលើមូលបត្រមួយ ត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

**ប្រការ ៥.- ការកែប្រែ ឬលុបចោលការបញ្ជាដែលបានបញ្ជូន**

សមាជិកអាចកែប្រែឬលុប ថ្លៃឬបរិមាណនៃបញ្ជាដែលបានដាក់។ នៅពេលមានការកែប្រែថ្លៃ ឬការ



Downloaded from http://www.khmerlaws.com

បង្កើនបរិមាណនៃបញ្ជា ពេលវេលាបញ្ជាក់ពីការទទួលបញ្ជា (Time Stamp) ដោយប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ត្រូវកំណត់សាជាថ្មី។

ការកែប្រែ ឬលុបបញ្ជា អាចធ្វើបានតែចំពោះបញ្ជាដែលមិនទាន់ត្រូវបានអនុវត្តប៉ុណ្ណោះ។

## ជំពូកទី ២

## ផ្សារមូលបត្រកម្មសិទ្ធិ

### ប្រការ ៦.- ម៉ោងជួញដូរ

ម៉ោងជួញដូរត្រូវចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ ១១:៣០ ព្រឹក។

ការអនុវត្តការជួញដូរត្រូវធ្វើឡើង ០២(ពីរ) ដងក្នុងមួយថ្ងៃ គឺនៅម៉ោង ០៩:០០ ព្រឹក និង ១១:៣០ ព្រឹក។

### ប្រការ ៧.- ថ្ងៃជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

### ប្រការ ៨.- នីតិវិធីនៃការបញ្ជា

ក្នុងករណីដែលសមាជិកមួយដាក់បញ្ជាទៅ **ផ.ម.ក.** សមាជិកនោះត្រូវអនុវត្តនីតិវិធីដូចខាងក្រោម÷

១- ពិនិត្យមើលសាច់ប្រាក់ ឬមូលបត្រដែលអតិថិជនមាន ដើម្បីធានាការទូទាត់ឬការជួញដូរដែលពាក់ព័ន្ធនឹងការបញ្ជានោះ។

២- ពិនិត្យព័ត៌មានលម្អិតនៃបញ្ជាដូចមានចែងក្នុងប្រការ ៩ ។

៣- ដាក់បញ្ជាចូលទៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.**។

### ប្រការ ៩.- ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ត្រូវមានព័ត៌មានលម្អិតនីមួយៗដូចខាងក្រោម :

១- ឈ្មោះមូលបត្រ។

២- បរិមាណ។

៣- ថ្លៃ។

៤- ប្រភេទនៃបញ្ជា : បញ្ជាទិញ ឬបញ្ជាលក់។

៥- ប្រភេទនៃប្រតិបត្តិការ : ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក។

៦- លេខអត្តសញ្ញាណសមាជិក។

៧- លេខអត្តសញ្ញាណវិនិយោគិន។



Downloaded from http://www.khmerlaws.com

៨-លេខបញ្ជា។

៩-លេខគណនី។

១០-ក្នុងករណីបញ្ជាដើម្បីលុបឬកែប្រែ ត្រូវបញ្ជាក់លើបញ្ជានោះថាជាការលុប ឬជាការកែប្រែ ហើយត្រូវបញ្ជាក់លេខបញ្ជាដើមផងដែរ។

១១-លេខកូដចំណាត់ថ្នាក់វិនិយោគិន។

១២-លេខកូដសញ្ជាតិ និងលេខកូដចំណាត់ថ្នាក់វិនិយោគិន ចំពោះវិនិយោគិនបរទេស។

**ប្រការ ១០.- ឯកតាបញ្ជា ឯកតាគម្លាតថ្លៃ និងឯកតាជួញដូរ**

ឯកតាបញ្ជាគឺ ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

ឯកតាគម្លាតថ្លៃត្រូវកំណត់ដូចខាងក្រោម :

១-៥០ (ហាសិប)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៥០.០០០ (ប្រាំម៉ឺន)រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

២-២៥០ (ពីររយហាសិប) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៥០.០០០ (ប្រាំម៉ឺន) រៀល ប៉ុន្តែទាបជាង ៥០០.០០០ (ប្រាំសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៣-៥០០ (ប្រាំរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៥០០.០០០ (ប្រាំសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

ចំនួនឯកតាជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការគឺ ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

**ប្រការ ១១.- ថ្លៃមូលដ្ឋាន**

ថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ ត្រូវកំណត់ដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយ **គ.ម.ក.** :

១-ក្រៅពីថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិដូចមានក្នុងចំនុច ២ ដល់ ៥ ខាងក្រោម ថ្លៃមូល-ដ្ឋាននៃមូលបត្រកម្មសិទ្ធិគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

២-ក្នុងករណីមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូង ថ្លៃមូលដ្ឋានគឺជាថ្លៃជួញដូរលើកដំបូងដែលត្រូវកំណត់ដោយអនុលោមទៅតាមប្រការ ១៦ នៃវិធាននេះ។

៣-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលបានចែកភាគលាភជាមូលបត្រកម្មសិទ្ធិ ថ្លៃមូលដ្ឋានគឺថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម :

| |
|---|
| មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |



Downloaded from http://www.khmerlaws.com

| |
|---|
| **ចំណាំ**÷ មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ =ថ្លៃបិទ x ចំនួនមូលបត្រកម្មសិទ្ធិមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

៤-ក្នុងករណីមានការបង្កើនដើមទុនតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ថ្លៃមូលដ្ឋានគឺជាថ្លៃទទួលបានតាមរូបមន្តដូចខាងក្រោម :

| |
|---|
| [មូលធនូបនីយកម្មទីផ្សារមុនបង្កើនដើមទុន + (ថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ x ចំនួនមូលបត្រកម្មសិទ្ធិដែលបានបោះផ្សាយលក់បន្ថែម)] / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបង្កើនដើមទុន |

៥-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលមានការបម្លែង (ការបំបែក ការបង្រួម ឬកាត់បន្ថយដើមទុនមូលបត្រកម្មសិទ្ធិ) ថ្លៃមូលដ្ឋានគឺ ជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម :

| |
|---|
| ថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ x អនុបាតបម្លែង |
| អនុបាតបម្លែង (Split Ratio) = ចំនួនមូលបត្រកម្មសិទ្ធិមុនបម្លែង / ចំនួនមូលបត្រកម្មសិទ្ធិក្រោយបម្លែង |

ក្នុងករណីថ្លៃមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវកំណត់ស្មើនឹងឯកតាគម្លាតថ្លៃ។

**ប្រការ ១២.- ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ**

ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ គឺត្រូវស្មើនឹងទឹកប្រាក់ ដែលគណនាដោយ ±៥% (បូក ឬ ដក ប្រាំភាគរយ) នៃថ្លៃមូលដ្ឋាន ហើយទឹកប្រាក់ដែលទាបជាងឯកតាគម្លាតថ្លៃត្រូវបានកាត់ខ្ទង់ចេញ។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០០ (មួយពាន់) រៀល ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃគឺស្មើនឹង ៥០ (ហាសិប) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ករណីដែលមូលបត្រកម្មសិទ្ធិត្រូវបានដកចេញពីការចុះបញ្ជីលក់មូលបត្រ ឬបានព្យួរពីការជួញដូរអស់រយៈពេលវែង ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិឡើងវិញ ឬការជួញដូរមូលបត្រកម្មសិទ្ធិឡើងវិញ ត្រូវធ្វើការកំណត់ថ្លៃមូលដ្ឋានដូចមានចែងក្នុងប្រការ ១៦ នៃវិធាននេះ។

**ប្រការ ១៣.- គោលការណ៍ដេញថ្លៃ**

រាល់ការជួញដូរត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ (Single-Price Auction)។



Downloaded from http://www.khmerlaws.com

អាទិភាពនៃបញ្ជាទិញ និងបញ្ជាលក់ តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម :

១-បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២-ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ទោះបីជាមានចែងក្នុងកថាខណ្ឌទី ២ ក៏ដោយ អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់ ត្រូវបានកំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា :

១-ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម :

ក-រាល់បញ្ជាទិញដែលមានថ្លៃស្មើនឹងដែនកំណត់ថ្លៃខាងលើ (ថ្លៃមូលដ្ឋាន + ៥%)។

ខ-រាល់បញ្ជាលក់ដែលមានថ្លៃស្មើនឹងដែនកំណត់ថ្លៃខាងក្រោម (ថ្លៃមូលដ្ឋាន - ៥%)។

២-ចំពោះបញ្ជាព្រមពេលគ្នាដូចមានចែងនៅក្នុងចំណុច១ នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះ បញ្ជាដែលមានបរិមាណច្រើនជាងមានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណីបញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល ផ.ម.ក. ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

៣-ការបែងចែងបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុច ១ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចមានចែងក្នុងចំណុច ២ នៃកថាខណ្ឌនេះ ដូចខាងក្រោម÷

ក-១០០ (មួយរយ) ដង នៃឯកតាជួញដូរ។

ខ-៥០០ (ប្រាំរយ) ដង នៃឯកតាជួញដូរ។

គ-១០០០ (មួយពាន់) ដង នៃឯកតាជួញដូរ។

ឃ-៥០ (ហាសិប) ភាគរយ នៃបរិមាណដែលនៅសល់។ ក្នុងករណីនេះ ប្រសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

ង-បរិមាណដែលនៅសល់ទាំងអស់ ត្រូវផ្តល់ឱ្យតាមអាទិភាព។

**ប្រការ ១៤.- វិធីសាស្ត្រ និងយន្តការនៃការអនុវត្តការជួញដូរ**

ការជួញដូរត្រូវបានអនុវត្តនៅថ្លៃកំណត់មួយ (ដែលហៅថា ថ្លៃផ្គូផ្គង ឬ Matched Price) ដែលនៅថ្លៃនោះ បរិមាណសរុបនៃបញ្ជាលក់ ត្រូវបានផ្គូផ្គងនឹងបរិមាណសរុបនៃបញ្ជាទិញ ដោយអនុវត្តទៅតាមលំដាប់នៃអាទិភាពដូចខាងក្រោម÷

១-អាទិភាពទី ១ : បរិមាណសរុបនៃបញ្ជាលក់ដែលមានថ្លៃទាបជាងថ្លៃផ្គូផ្គង និងបរិមាណ



Downloaded from http://www.khmerlaws.com

សរុបនៃបញ្ជាទិញ ដែលមានថ្លៃខ្ពស់ជាងថ្លៃផ្គូផ្គង។

២-អាទិភាពទី ២: ក្នុងករណីនៃបញ្ជាលក់ ឬបញ្ជាទិញ ដែលមានថ្លៃស្មើនឹងថ្លៃផ្គូផ្គង បរិមាណមូលបត្រដែលត្រូវអនុវត្តត្រូវកំណត់ដូចខាងក្រោម:

ក-បរិមាណសរុបនៃបញ្ជាលក់ ឬ បរិមាណសរុបនៃបញ្ជាទិញ និង

ខ-ចាប់ពី ១ ឯកតាជួញដូរនៃភាគីម្ខាងទៀត។

ក្នុងករណីដែលមានចំនួនថ្លៃផ្គូផ្គងលើសពី ១ (មួយ) ថ្លៃផ្គូផ្គងត្រូវបានជ្រើសរើសក្នុងចំណោមថ្លៃដូចខាងក្រោម÷

១-ថ្លៃជួញដូរចុងក្រោយ ប្រសិនបើមានថ្លៃផ្គូផ្គងណាមួយស្មើនឹងថ្លៃជួញដូរចុងក្រោយនេះ។

២-ថ្លៃដែលនៅក្បែរថ្លៃជួញដូរចុងក្រោយជាងគេ ប្រសិនបើគ្មានថ្លៃផ្គូផ្គងណាដែលស្មើនឹងថ្លៃជួញដូរចុងក្រោយ។

## ប្រការ ១៥.- ការកែតម្រូវលើកំហុសប្រតិបត្តិការ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាព័ត៌មានលម្អិតអំពីការជួញដូរនេះអាចត្រូវបានធ្វើការកែតម្រូវ។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា: កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវធ្វើការកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.** : ក្នុងករណីនេះ **ផ.ម.ក.** ត្រូវធ្វើការកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់ដែលបណ្តាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក: កំហុសឆ្គងត្រូវធ្វើការកែតម្រូវបន្ទាប់ពីសមាជិកនោះ ទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែលបញ្ជាក់ពីមូលហេតុ ឬឯកសារភស្តុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់នៃថ្ងៃជួញដូរបន្ទាប់។

## ប្រការ ១៦.- វិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូង

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូង ត្រូវស្ថិតនៅចន្លោះ ៩០% (កៅសិបភាគរយ) និង ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៣
## ការគ្រប់គ្រងទីផ្សារ

**ប្រការ ១៧.- ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ**

ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម÷

១-ថ្លៃបើក និង ថ្លៃបិទ។

២-បរិមាណ និង តម្លៃសរុបនៃការជួញដូរ។

ផ.ម.ក. អាចធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការសម្រេចចិត្តវិនិយោគ ដើម្បីការពារផលប្រយោជន៍វិនិយោគិន។

**ប្រការ ១៨.- ព័ត៌មានដែលត្រូវជូនដំណឹងទៅសមាជិក**

ផ.ម.ក. ត្រូវជូនដំណឹងទៅសមាជិករបស់ខ្លួននូវព័ត៌មាននីមួយៗដូចខាងក្រោម :

១-វិធានប្រតិបត្តិការរបស់ ផ.ម.ក. និងវិសោធនកម្មដែលអាចកើតមាន។

២-មូលបត្រចុះបញ្ជីលក់ដំបូង មូលបត្រចុះបញ្ជីលក់បន្ថែម មូលបត្រដកចេញពីការចុះបញ្ជីលក់ និងមូលបត្រដែលត្រូវបានព្យួរការជួញដូរ។

៣-ការបិទទីផ្សារជាបណ្ដោះអាសន្ន ការផ្អាកដំណើរការទីផ្សារ និងការផ្លាស់ប្ដូរម៉ោងជួញដូរ។

៤-សមាជិកដែលត្រូវបានអនុញ្ញាត ឬសមាជិកដែលបានដកខ្លួនពីសមាជិកភាព ឬត្រូវបានដកចេញពីសមាជិកភាព។

៥-សមាជិកដែលត្រូវបានព្យួរពីការជួញដូរ និងការអនុញ្ញាតឱ្យជួញដូរឡើងវិញ។

៦-ព័ត៌មានលម្អិតនៃការជួញដូររួមមាន: ឈ្មោះមូលបត្រ បរិមាណនិងថ្លៃជួញដូរ ប្រភេទបញ្ជាទិញ ឬលក់ ប្រតិបត្តិការសម្រាប់គណនីសមាជិក ឬគណនីអតិថិជន។

ផ.ម.ក. ត្រូវរក្សាទុករាល់ព័ត៌មានទាក់ទងនឹងបញ្ជា ការកែតម្រូវកំហុសប្រតិបត្តិការ និងព័ត៌មានលម្អិតលើការជួញដូរ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

**ប្រការ ១៩.- ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់សមាជិក**

សមាជិកទាំងអស់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ និងវិធាននេះ។

**ប្រការ ២០.- កាលបរិច្ឆេទអិចឌីវីដិនដ៍ ឬអិចរាយថ៍**

កាលបរិច្ឆេទអិចឌីវីដិនដ៍(Ex-Dividend) ឬអិចរាយថ៍(Ex-Right) គឺកាលបរិច្ឆេទជួញដូរនៅរយៈ



Downloaded from http://www.khmerlaws.com

កាល ០១ (មួយ) ថ្ងៃ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ (Record Date)។

**ប្រការ ២១.- អ្នកតំណាងនៅក្នុងទីផ្សារ**

សមាជិកនីមួយៗត្រូវតែងតាំងអ្នកតំណាងនៅក្នុងទីផ្សារយ៉ាងហោចណាស់ ០១ (មួយ) រូប ដែលនឹងត្រូវបណ្តុះបណ្តាលដោយ **ផ.ម.ក.** ដើម្បីប្រើប្រាស់ប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ដែលរៀបចំសម្រាប់សមាជិក ហើយដែលនឹងត្រូវធ្វើការនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.**។

សមាជិកនីមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកតំណាងនៅក្នុងទីផ្សាររបស់ខ្លួននៅ **ផ.ម.ក.**។ មានតែអ្នកតំណាងនៅក្នុងទីផ្សារទេ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិកដែលស្ថិតនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.**។

## ជំពូកទី ៤
## ការត្រួតពិនិត្យការជួញដូរមូលបត្រ

**ប្រការ ២២.- យន្តការបង្ការរបស់ ផ.ម.ក**

ដើម្បីធានាបាននូវបរិស្ថានជួញដូរដែលមានយុត្តិធម៌ និងការពារវិនិយោគិន **ផ.ម.ក.** អាចដាក់ចេញនូវយន្តការបង្ការមួយចំនួនដើម្បីទប់ស្កាត់ការអនុវត្តការជួញដូរមូលបត្រមិនស្មោះត្រង់ ឬមិនប្រក្រតីរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅ **ផ.ម.ក.**។

**ប្រការ ២៣.- ការឃ្លាំមើលមូលបត្រ** (Stock Watch)

**ផ.ម.ក.**ត្រូវធ្វើការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ។

ការកំណត់អត្តសញ្ញាណមូលបត្រ ដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតីត្រូវបានធ្វើឡើងដោយគិតបញ្ចូលនូវព័ត៌មានមួយចំនួនដូចជា របៀបនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំនៃការជួញដូរ ព្រមទាំងកម្រិតនៃទំនាក់ទំនងរវាងថ្លៃទីផ្សារនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។

**ប្រការ ២៤.- កម្រៃសេវាប្រតិបត្តិការ**

សមាជិកត្រូវបង់កម្រៃសេវាប្រតិបត្តិការដែលពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាប្រាក់កម្រៃសេវាប្រតិបត្តិការ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ ត្រូវបានកំណត់ដូចខាងក្រោម :



Downloaded from http://www.khmerlaws.com

១-អត្រា: ប្រាក់កម្រៃសម្រាប់សេវាផ្គូផ្គងមូលបត្រកម្មសិទ្ធិ ត្រូវគណនាលើទឹកប្រាក់នៃការផ្គូផ្គងដែលបានទូទាត់ (ទឹកប្រាក់នៃប្រាក់កម្រៃដែលគណនា ត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ២៥/១០.០០០ ឬ ០,២៥% (សូន្យក្បៀសម្ភៃប្រាំភាគរយ)។

២-អ្នកត្រូវបង់ប្រាក់: ក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ **ផ.ម.ក.**។

៣-ពេលវេលាបង់ប្រាក់: ម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

*****



Downloaded from http://www.khmerlaws.com